# សារបានខ្លះៗនៃវិហារបុរាណវត្តកណ្ដឹង

វត្តកណ្ដឹង ឬអ្នកខ្លះហៅថាវត្តគរ ស្ថិតនៅក្នុងសង្កាត់គរ ក្រុងបាត់ដំបង ខាងត្បូងសាលាខេត្ត។[១] បើទោះបីពុំមានឯកសារដាក់លាក់ក៏ដោយក្ដី គេយល់ឃើញថាវត្តនេះកកើតឡើងដំបូងគេនៅបាត់ដំបង ហើយមកដល់សព្វថ្ងៃមានរឿងតំណាលជាច្រើនពាក់ព័ន្ធនឹងការកសាងវិហារ។ អ្នកខ្លះអះអាងថាគិតមកដល់បច្ចុប្បន្ន វត្តកណ្ដឹងមានវិហារចំនួនបី។ វិហារទី១ ស្ថិតនៅខាងជើងទន្ទឹមនឹងវិហារទី២ តែទំនងត្រូវគេបំផ្លាញចោលក្នុងសម័យសង្គ្រាម។ រីឯវិហារទី២ ជាវិហារចាស់បច្ចុប្បន្នដែលស្ថិតនៅខាងមុខវិហារទី៣។ ចំពោះវិហារទី២ ជាវិហារបុរាណប្រកបដោយក្បូរក្បាច់រចនាយ៉ាងវិចិត្រនេះ គេយល់ថាកសាងឡើងនៅរវាងដើមសតវត្សទី២០ ក្នុងសម័យលោកម្ចាស់ គ្រាដែលទឹកដីបាត់ដំបងស្ថិតនៅជាចំណុះសៀម។

យោងតាមឯកសារបាត់ដំបងសម័យលោកម្ចាស់ឱ្យដឹងថា មុនមានវិហារថ្មីសព្វថ្ងៃ វត្តកណ្ដឹងមានវិហារពីរទន្ទឹមគ្នាតាំងពីបុរាណ។ អ្នកនិពន្ធ តូច ឈួង បញ្ជាក់ថាវិហារខាងជើងស្ថាបនាយូរយារហើយ រីឯវិហារខាងត្បូងស្ថាបនាដោយលោកស្រី អ៊ឹង ភរិយាដើមរបស់លោកម្ចាស់គទាធរឈុំ ជាអតីតស្ដេចត្រាញ់ចុងក្រោយត្រួតបាត់ដំបង។ គេតំណាលថា ហេតុដែលនាំឱ្យកសាងវិហារនេះ គឺដោយសារលោកម្ចាស់មានភរិយាច្រើន (ប្រហែលជាង៤០នាក់) បណ្ដាលឱ្យលោកស្រី អ៊ឹង ជាភរិយាដើមឈឺចាប់កើតទុក្ខរីងរៃ រហូតកើតជាជំងឺម្យ៉ាងគឺ "ខ្លាច" ហើយខ្លាចគ្រប់សព្វសារពើ ជាពិសេសខ្លាចសំឡេងឆ្កែលូ។ ពេលនោះគេតែងចាត់ឱ្យសម្លាប់ឆ្កែទាំងអស់ដែលលូឮដល់លោកស្រី។ រីឯលោកព្រះឃ្លាំងជាឪពុកបានរិះរកគ្រប់មធ្យោបាយព្យាបាលកូនស្រី និងបានទៅបន់ស្រន់ព្រះអង្គខ្មៅ ដែលជាព្រះពុទ្ធរូបស័ក្តិសិទ្ធិនៅវត្តកណ្ដឹង ដោយប្រាថ្នាសុំសាងវិហារមួយថ្វាយ បើកាលណាកូនស្រីបានធូរស្បើយ។ ក្រោយពេលលោកស្រី អ៊ឹង បានធូរស្បើយបន្តិច គាត់ក៏ចាត់សង់វិហារមួយនៅខាងត្បូងព្រះវិហារចាស់ ហើយគង់វង្សរហូតមកដល់សព្វថ្ងៃ។[២]

---

[១] សាលាខេត្តបាត់ដំបងបច្ចុប្បន្ន ជាអតីតផ្ទះរបស់លោកម្ចាស់គទាធរឈុំ

[២] តូច ឈួង ១៩៩៤: ១៦៩-១៧១, ២០៤

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១ វិហារវត្តកណ្ដឹង ថតឆ្នាំ១៩២៤ (រូប៖ សារមន្ទីរជាតិ)



រូបលេខ២ វិហារវត្តកណ្ដឹងដែលគង់វង្សមកដល់សព្វថ្ងៃ

បើពិនិត្យផ្នែកខ្វះនៃសំណង់ និងចំណារខ្វីៗលើជញ្ជាំង គេដឹងថាវិហារបុរាណវត្តកណ្ដឹងធ្លាប់បានជួសជុលច្រើនគ្រាមកហើយ។ តាមរយៈរូបថតក្នុងឆ្នាំ១៩២៤ គេចាត់ទុកវិហារនេះជាប្រភេទវិហារមណ្ឌប (រូបលេខ១)។ លំនាំវិហារបែបនេះ គេសង្កេតឃើញនិយមនៅដើមសតវត្សទី២០ ហើយបានបន្តវិវឌ្ឍមកហូរហែដល់សព្វថ្ងៃ។[៣] បុស្បុកវិហារមណ្ឌប គេច្រើនធ្វើថ្នាក់ៗ និងកំពូលស្រួចខ្ពស់។ ផ្អែកលើរូបថតឯកសារនេះ វិហារដើមវត្តកណ្ដឹង មានដំបូលប្រក់ក្បឿងស្រកាលេញ ខាងកើតមានជហ្វា៣ ខាងលិចមានជហ្វា៣ ហើយខាងជើង និងខាងត្បូងមានជហ្វាម្ខាង២ ព្រមទាំងមានបំពាក់នាគដងក្តារតាមចុងចែងដំបូលនីមួយៗ។ រីឯបុស្បុកលម្អលើដំបូល ហាក់ស្រដៀងនឹងកំពូលបុស្បុកវិហារវត្តដំរីសសព្វថ្ងៃ ដែលស្ថិតនៅខាងជើងសាលាខេត្ត។





រូបលេខ៣ ជហ្វា និងនាគព្រំដំបូល



រូបលេខ៤-៥ ក្បាច់លម្អហោជាង និងចម្លាក់ទ្រហោជាងខាងកើត

---

[៣] ព្រាប ចាន់ម៉ារ៉ា ២០១៧: ២៩

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

 

រូបលេខ២៦-៧ ហោជាងខាងលិច និងក្បាច់រចនាលម្អលើហោជាង

សព្វថ្ងៃ វិហារវត្តកណ្ដឹងនៅសល់ត្រឹមតែជហ្វា៤ លំនាំស្រដៀងវិហារវត្តសំរោងក្នុង និងវត្តបាឡាត់ តែវិហារវត្តនេះពុំមាននាគដងក្ដារតាមចុងចែងដំបូលផ្នែកខាងលើដូចមុនឡើយ ហើយជំនួសដោយនាគលើព្រំដំបូលពីរថ្នាក់ខាងក្រោម(រូបលេខ២៤-៣)។ តាមរយៈឯកសារគេយល់ថា ការជួសជុលដូរដំបូលវិហារនេះ ធ្វើឡើងនៅក្នុងឆ្នាំ១៩៦៩។[៤] ក្នុងគ្រានោះគេបានយកបុស្បុក និងហោជាងចំហៀងសងខាងចេញ ដោយរក្សាទុកតែហោជាងខាងកើត និងខាងលិចប៉ុណ្ណោះ។ ហោជាងទាំងពីរ សុទ្ធសឹងរចនាពីឈើប្រកបដោយក្បាច់រចនាយ៉ាងរស់រវើក។ ផ្ទៃហោជាង លម្អដោយក្បាច់ភ្ញីទេសព័ទ្ធជុំវិញជើងពានទ្រគម្ពីរនៅចំផ្នែកកណ្ដាល។ សងខាងជើងពាន មានរូបសត្វទេពអមសងខាង និងរូបទេវតានៅផ្នែកខាងលើ។ នៅផ្នែកខាងលើគម្ពីរ មានរូបទេព (?) លេចឡើងពាក់កណ្ដាលខ្លួន និងពន្លឺឆព្វណ្ណរង្សី។ ហោជាងខាងកើត គេឃើញមានចម្លាក់រូបគ្រុឌ និងយក្សទ្រហោជាងយ៉ាងអង់អាច (រូបលេខ២៤-៧)។ ប៉ុន្តែហោជាងខាងលិច ពុំមានចម្លាក់បែបនេះទេ។

ដោយឡែក រចនាសម្ព័ន្ធសំណង់ផ្នែកខាងក្រោម គេបានរក្សាដូចដើមស្ទើរតែទាំងស្រុង។ សូមបញ្ជាក់ថាគ្រឿងបង្គុំដំបូលផ្នែកខាងលើនៃវិហារនេះ គឺជាឈើទាំងអស់ តែផ្នែកខាងក្រោមជាបេតុង ហើយសង់នៅលើផ្ទៃដីរាបស្មើពុំមានខឿនខ្ពស់ច្រើនជាន់ដូចវិហារផ្សេងឡើយ។ រីឯសសររបៀងជុំវិញ ជាប្រភេទសសរមូលធំៗ លម្អក្បាលសសរតាមលំនាំសិល្បៈបស្ចិមប្រទេស (រូបលេខ២៨)។ ការលម្អលើទ្វារ និងបង្អួចផ្នែកខាងក្រោមមានលក្ខណៈ

[៤] Daniel Guéret & Dominique-Pierre Guéret 2017: 164

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាល្បាក់កោងផ្កាប់លំនាំដូចដើមព្យញ្ជនៈក"្"ៗ ចំពោះសសរខាងក្នុង ជាសសរឈើមូលដូចវិហារឈើទូទៅផ្សេងទៀតដែរ។



រូបលេខ៨ របៀងជុំវិញវិហារ



រូបលេខ៩ ផ្នែកខាងក្នុងវិហារ និងព្រះជីវ៍





រូបលេខ១០-១១ ទឹកដៃគំនូរឆ្នាំ១៩៨៥ និយាយអំពីឈុតខ្លះក្នុងពុទ្ធប្រវត្តិ

តាមរយៈសំណោរខ្ចីៗ គេអាចដឹងថាគំនូរខាងក្នុងវិហារគូរក្នុងឆ្នាំ១៩៨៥ ដោយជាងមួយក្រុមមានឈ្មោះ ស៊ុន សិត, ទីន សុស, និង ប៉ិច ប៊ុនឆ្លួន។ ការគូរគំនូរនេះ ធ្វើឡើងស្របគ្នានឹងការជួសជុលលាបពណ៌បល្ល័ង្កព្រះជីវ៍ និងពិដានខាងលើ ដែលជាសទ្ធារបស់លោកយាយម្នាក់ឈ្មោះ មាញ (រូបលេខ៩-១១)។ ខ្លឹមសារគំនូរទាំងនោះ សុទ្ធសឹងជាឈុត

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*ផ្សេងៗក្នុងពុទ្ធប្រវត្តិ។ ប៉ុន្តែយ៉ាងណាក៏ដោយ ផុតពីនោះមក វិហារនេះធ្លាប់ជួសជុលពីរលើកទៀត ពោលគឺនៅក្នុងឆ្នាំ១៩៩៧ម្ដង និងក្នុងឆ្នាំ២០០២ ម្ដងទៀត។*

*ដូច្នេះសរុបមក តាមរយៈសារបានខ្លះៗ និងលក្ខណៈសិល្បៈស្ថាបត្យកម្មវិហារវត្តកណ្ដឹង គេអាចយល់ជារួមថា វត្តកណ្ដឹងជាបូជនីយដ្ឋានដ៏ស័ក្តិសិទ្ធិ ហើយការកសាង និងជួសជុលជាបន្តបន្ទាប់កន្លងមក ប្រហែលធ្វើឡើងតាមលំអានប្រពៃណី ដែលពុទ្ធសាសនិកមានជំនឿ និងជ្រះថ្លា ចូលមកជ្រោមជ្រែងទំនុកបម្រុងជួសជុលថែទាំកុដិវិហារសទ្ធាជូនតារក្សាទុកជាសម្បត្តិគរុភណ្ឌឱ្យគង់វង្សតមកជាអង្វែង។ ទំនៀមបែបនេះ មានតាំងពីបុរាណជាពិសេសក្នុងសតវត្សទី១៦ ព្រះអង្គចន្ទយាងទៅជួសជុល ឆ្លាក់បង្ហើយចម្លាក់លើជញ្ជាំងអង្គរវត្តជាដើម។ ទន្ទឹមនឹងនេះ ការគូររឿងពុទ្ធប្រវត្តិ ឬសាច់រឿងផ្សេងៗលើជញ្ជាំងវិហារក្នុងគំនិតបុរាណ ប្រហែលពុំមែនជាការចាំបាច់អត់ពុំបានឡើយ ដ្បិតមានវិហារបុរាណខ្លះពុំមានគំនូរ ឬគូរនៅពេលក្រោយដូចជាវិហារវត្តដំណាក់ (សៀមរាប) វិហារវត្តទន្ទាប់ (បន្ទាយមានជ័យ) និងវិហារវត្តរោងដំរី (ព្រៃវែង)ជាដើម៕*

## ឯកសារយោង

*តូច ឈួង*

*១៩៩៤, បាត់ដំបងសម័យលោកម្ចាស់, មជ្ឈមណ្ឌលបូព៌ា-បស្ចិម, ហូណូលូលូ រដ្ឋហាវ៉ៃ*

*ព្រាប ចាន់ម៉ារ៉ា*

*២០១៧, សំណង់នៅតាមវត្ត, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ*

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION